Declassified to Public
12 June 2020





**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/០៧-០៩-២០០៩-អវតក/កសចស |
| **ដាក់ទៅ** | : | សហចៅក្រមស៊ើបអង្កេត |
| **ថ្ងៃដាក់** | : | ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 25-Nov-2016, 14:44
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សម្ងាត់**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត :**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ**
**ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Judge Mark B. HARMON

**ចម្លងជូន:**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

## សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៥៣ និង ៥៥ សហព្រះរាជអាជ្ញាអន្តរជាតិ ដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះ ក្នុងគោលបំណងបំពេញបន្ថែម និងបញ្ជាក់បំភ្លឺពីបញ្ហាអង្គហេតុនានាដែលត្រូវស៊ើបសួរដោយសហចៅក្រមស៊ើបអង្កេត ("សចសអ" ឬ "កសចស") ក្នុងសំណុំរឿង០០៤។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះ បង្ហាញជូនភស្តុតាងអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ នៅក្នុងបណ្តាស្រុកដែលស្ថិតនៅក្រោមការត្រួតត្រា ឬសិទ្ធិអំណាចរបស់ជនសង្ស័យក្នុងសំណុំរឿង ០០៤ ផ្អែកតាមភស្តុតាងដែលទទួលបានតាំងពីដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីបី ("3rd IS") រួមទាំងកំណត់ហេតុស្តាប់ចម្លើយសាក្សី ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងនានាពីសំណុំរឿង ០០២ និង ០០៤។ ឧក្រិដ្ឋកម្មដែលបានរៀបរាប់ក្នុងកថាខណ្ឌ២ ដល់១២ ខាងក្រោម ស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ដូច្នេះសូមស្នើឲ្យស៊ើបសួរទៅលើឧក្រិដ្ឋកម្មទាំងនេះជាផ្នែកនៃសំណុំរឿងលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស។

## ឧក្រិដ្ឋកម្ម

*ស្រុកកំពង់សៀម (តំបន់ ៤១)*

២. មានប្រភពជាច្រើនបានត្អូញត្អែរអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងស្រុកកំពង់សៀម (ផ្នែកនៃតំបន់ ៤១ នៃភូមិភាគកណ្តាល) នៅក្នុងសម័យកាលដែល **អោម អាន** ធ្វើជាលេខាតំបន់ ៤១ (ដើមឆ្នាំ ១៩៧៧ ដល់ខែមករា ឆ្នាំ១៩៧៨)[1]។ អាពាហ៍ពិពាហ៍ទាំងនោះមានការពាក់ព័ន្ធនឹងគូស្រករជាច្រើន

---

[1] **D3/19** កំណត់ហេតុស្តាប់ចម្លើយ វង សុគន្ធ ដោយ កសចស, A8។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ កែវ ធារី [KEO Theary] (សំណុំរឿង០០២), E3/4963 ត្រង់ ENG 00864750 (សំណុំរឿង០០៤ **D5/217** ត្រង់ ENG 00864750), និងព័ត៌មានបន្ថែម, D22/2564a (សំណុំរឿង០០៤ **D5/217.2** ត្រង់ ENG 00842816) [*ហើយក៏បាន ដាក់ពាក្យសុំតាំង ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ ផងដែរ - សូមមើល D5/217/3*]។ ព័ត៌មានបន្ថែមរបស់ ស៊ូ រ៉ុន [SOU Ron] (សំណុំ រឿង ០០២), D22/3342b (សំណុំរឿង០០៤ **D191.1.88** ត្រង់ ENG 00596542) [*ហើយក៏បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ ផងដែរ - សូមមើល D5/173/3*]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ញឹប ទ្រី [NHIP Try] (សំណុំរឿង០០២), D22/3344/1 (សំណុំរឿង០០៤ **D191.1.61** ត្រង់ ENG 00564586-87) និងព័ត៌មាន បន្ថែម, D22/3344b (សំណុំរឿង០០៤ **D191.1.62** ត្រង់ ENG 00596543) [*ហើយក៏បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ ផងដែរ - សូមមើល D5/172/3*]; ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឃី ស្រាន [KHY Srean] (សំណុំរឿង០០២), D22/2039/1 (សំណុំរឿង០០៤ **D191.1.38** ត្រង់ ENG 00544177-78); *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ*

ពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីរបស់ វ៉ា លីម ហ៊ុន [VA Lim Hun] (សំណុំរឿង០០២), D22/2548/1 (សំណុំរឿង០០៤ **D191.1.101** ត្រង់ ENG 00552373-74), ព័ត៏មានបន្ថែមរបស់, D22/2548b (សំណុំរឿង០០៤ **D191.1.102** ត្រង់ ENG 00596477-78) [*ហើយ ក៏បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ ផងដែរ - សូមមើល D5/13/3*]; ពាក្យសុំតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណីរបស់ ពិន ដន [PIN Dân] (សំណុំរឿង០០២), E3/4961 ត្រង់ ENG 00864764 (សំណុំរឿង០០៤ **D5/230** ត្រង់ ENG 00864764), និងព័ត៏មានបន្ថែម, E3/4962 (សំណុំរឿង០០៤ **D5/230.1** ត្រង់ ENG 00842817-18); ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឃី ហ៊ាន (KHY Hean) (សំណុំរឿង០០២), D22/2550/1 (សំណុំរឿង០០៤ **D191.1.35** ត្រង់ ENG 00552405-06), និងព័ត៏មានបន្ថែម, D22/2550b (សំណុំរឿង០០៤ **D191.1.37** ត្រង់ ENG 00596481); ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពាញ ស្រ៊ុន (PEANH Srun) (សំណុំរឿង០០២), D22/2553/1 (សំណុំរឿង០០៤ **D191.1.66** ត្រង់ ENG 00552447-48), និងព័ត៏មានបន្ថែម, D22/2553b (សំណុំរឿង០០៤ **D191.1.67** ត្រង់ ENG 00596482) [*ហើយក៏បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ ផងដែរ - សូមមើល D5/208/3*]; និងព័ត៏មានបន្ថែមរបស់ អ៊ូ យ៉ន (OU Yân) (សំណុំរឿង០០២), D22/3373b (សំណុំរឿង០០៤ **D191.1.65** ត្រង់ ENG 00596553); ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ ទូច មឿន (TOUCH Moeun) (សំណុំរឿង០០២), D22/2547/1 (សំណុំរឿង០០៤ **D191.1.97** ត្រង់ ENG 00552359-60) [*ហើយក៏បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុង សំណុំរឿង ០០៤ ផងដែរ - សូមមើល D5/227/3*]; ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជឹម ចក់ (CHIM Chork) (សំណុំ រឿង០០២), D22/3734/1 (សំណុំរឿង០០៤ **D191.1.10** ត្រង់ ENG 00569362-63); ព័ត៏មានបន្ថែមរបស់ ហ៊ួត គីមណៃ (HUOT Kimnai) (សំណុំរឿង០០២), D22/882a (សំណុំរឿង០០៤ **D191.1.12** ត្រង់ ENG 00854027-29); ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ិច ម៉ន (MECH Mân) (សំណុំរឿង០០២), D22/3336/1 (សំណុំរឿង០០៤ **D191.1.42**ត្រង់ENG 00564494-95); ព័ត៏មានបន្ថែមរបស់ កឿត ឆាយ (KOEUT Chhay) (សំណុំរឿង០០២), D22/1273b (សំណុំរឿង០០៤ **D191.1.40** ត្រង់ ENG 00596394-95); ព័ត៏មានបន្ថែមរបស់ ភុន បាន់ (PHUN Bann) (សំណុំរឿង០០២), D22/1264b (សំណុំរឿង០០៤ **D191.1.76** ត្រង់ ENG 00596388-89); ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ិន ស្រាំង (IN Sraing) (សំណុំរឿង០០២), D22/2491/1 (សំណុំរឿង០០៤ **D191.1.22** ត្រង់ ENG 00550791-92); ពាក្យសុំតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណីរបស់ ផុន អឿន (PHON Oeurn) (សំណុំរឿង០០២), D22/3346/1 (សំណុំរឿង០០៤ **D191.1.74** ត្រង់ ENG 00580276-77) [២០គូទៀត ត្រូវបានបង្ខំឲ្យរៀបការ]; ព័ត៏មានបន្ថែមរបស់ ណាង ឆេន (NANG Chhen) (សំណុំរឿង០០២), D22/3367b (សំណុំរឿង០០៤ **D191.1.59** ត្រង់ ENG 00596547) [សាក្សីបានឃើញ “ការរៀបការដោយបង្ខំប្រហែល២០ ទៅ ៣០គូ” នៅក្នុងឃុំក្រឡា]; ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡុង រ៉ន (LONG Rân) (សំណុំរឿង០០២), D22/3398/1 (សំណុំរឿង០០៤ **D191.1.51** ត្រង់ ENG 00580330-31) [សាក្សីបានឃើញ “គូស្រករជាច្រើន” ត្រូវបានគេបង្ខំឲ្យរៀបការចាប់ពីឆ្នាំ១៩៧៧-៧៨ នៅក្នុងឃុំក្រឡា]; ពាក្យបណ្តឹងរបស់ ស៊ុំ ប៉ិត (SUM Pet) (សំណុំរឿង០០២), D230/2/4.2.282a ត្រង់ ERN ជាភាសាអង់គ្លេស 00978645 (សំណុំរឿង០០៤ **D5/584** ត្រង់ ENG 00978645); ពាក្យបណ្តឹងរបស់ សាន នាង (SAN Neang) (សំណុំរឿង០០២), D230/2/4.2.285b (សំណុំរឿង០០៤ **D191.1.107** ត្រង់ ENG 00629101) [*បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ - សូមមើល D5/324/2*]; កំណត់ហេតុស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ របស់ ណាត ហឿន (NAT Hoeun) ដោយ កសចស, D43 ត្រង់ ERN ជាភាសាអង់គ្លេស 00797024 (សំណុំរឿង០០៤ **D191.1.112** ត្រង់ ENG 00797024)។ ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីខាងក្រោម អាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកគាត់បានកើតឡើង នៅក្នុងស្រុកកំពង់សៀម ឬ ព្រៃឈរ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មុំ ស្រឿង (MOM Sroeurng) (សំណុំរឿង០០២), D22/3345/1 (សំណុំរឿង០០៤ **D191.1.56** ត្រង់ENG 00564601-02), និងព័ត៏មានបន្ថែម, D22/3345b (សំណុំរឿង០០៤

រហូតដល់៦០គូ ត្រូវបានគេបង្ខំឲ្យរៀបការនឹងគ្នាក្នុងពេលតែមួយ[2] ហើយអាពាហ៍ពិពាហ៍ទាំងនេះ ត្រូវបានរៀបចំ និងដឹកនាំធ្វើដោយប្រធានអង្គភាព និងកម្មាភិបាល បកក មូលដ្ឋានផ្សេងទៀត (ដែលពួកគេបានរាយការណ៍តាមឋានានុក្រមនៃខ្សែបញ្ជា ជូនទៅលេខាស្រុក ប្រាក់ យុទ្ធ និងលេខាតំបន់ **អោម អាន**)[3]។ ជនរងគ្រោះក្រោមអាពាហ៍ពិពាហ៍ដោយបង្ខំនេះ ត្រូវបានតាមដានដោយអ្នកឈ្លបយកការណ៍ ឬកងឈ្លប ដើម្បីធានាឲ្យប្រាកដថា ពួកគេពិតជាបានរួមដំណេកជាមួយគ្នា ដែលនេះគឺជាកាលៈទេសៈដែលមានលក្ខណៈបង្ខិតបង្ខំជាប់មកជាមួយស្រេច ដែលពួកកម្មាភិបាល បកក បានបង្កើតឡើង និងថែទាំ[4]។ ប្រភពមកពីស្រុកនេះ ក៏បានបញ្ជាក់ផងដែរថា អ្នកទោសស្ត្រីត្រូវបានគេរំលោភសេពសន្ថវៈមុននឹងត្រូវបានគេសម្លាប់ចោល[5]។

---

**D191.1.57** ត្រង់ ENG 00596544) [*ហើយក៏បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ ផងដែរ - សូមមើល D5/33/3*]; ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ផាន យិន (PHAN Yin) (សំណុំរឿង០០២), D22/3725/1 (សំណុំរឿង០០៤ **D191.1.70** ត្រង់ ENG 00569296-97)។

[2] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឃី ស្រ៊ាន (KHY Srean) (សំណុំរឿង០០២), D22/2039/1 (សំណុំរឿង០០៤ **D191.1.38** ត្រង់ ENG 00544177-78) [៦០គូ]; ព័ត៌មានបន្ថែម របស់ កែវ ធារី (KEO Theary) (សំណុំរឿង០០២), D22/2564a (សំណុំរឿង០០៤ **D5/217.2** ត្រង់ ENG 00842816) [៥៧គូ]; ព័ត៌មានបន្ថែមរបស់ ជឹម ចក់ (CHIM Chork) (សំណុំរឿង០០២), D22/3734c (សំណុំរឿង០០៤ **D191.1.12** ត្រង់ ENG 00596582) [៥៧គូ]; ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ិន ស្រាំង (IN Sraing) (សំណុំរឿង០០២), D22/2491/1 (សំណុំរឿង០០៤ **D191.1.22** ត្រង់ ENG 00550791-92) [៥០គូ]; ព័ត៌មានបន្ថែមរបស់ អ៊ូ យ៉ន (OU Yân) (សំណុំរឿង០០២), D22/3373b (សំណុំរឿង០០៤ **D191.1.65** ត្រង់ ENG 00596553) [បង្ខំឲ្យរៀបការ៤៨គូ ទៀត នៅកន្លែងហូបបាយអង្គួចដី (Angkuonh Dei), ឃុំក្រឡា]; កំណត់ហេតុស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ របស់ ណាត ហឿន (NAT Hoeun) ដោយ កសចស, D43 ត្រង់ ERN ជាភាសាអង់គ្លេស 00797024 (សំណុំរឿង០០៤ **D191.1.112** ត្រង់ ENG 00797024) [រៀបការដោយបង្ខំចំពោះក្រុមមនុស្សប្រហែល៥០ ទៅ៦០គូ បានចាប់ផ្តើមក្នុងឆ្នាំ១៩៧៦ ឬ១៩៧៧ នៅក្នុងស្រុកកំពង់សៀម]។

[3] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ កែវ ធារី (KEO Theary) (សំណុំរឿង០០២), E3/4963 ត្រង់ ERN ជាភាសាអង់គ្លេស 00864750 (សំណុំរឿង០០៤ **D5/217** ត្រង់ ENG 00864750), និងព័តមានបន្ថែម, D22/2564a (សំណុំរឿង០០៤ **D5/217.2** ត្រង់ ENG 00842816); ព័ត៌មានបន្ថែមរបស់ ស៊ូ រ៉ុន (SOU Ron) (សំណុំរឿង០០២), D22/3342b (សំណុំរឿង០០៤ **D191.1.88** ត្រង់ ENG 00596542); ព័ត៌មានបន្ថែមរបស់ ហ៊ួត គឹមណៃ (HUOT Kimnai) (សំណុំរឿង០០២), D22/882a (សំណុំរឿង០០៤ **D191.1.16** ត្រង់ ENG 00854027-29); ពាក្យបណ្តឹងរបស់ សាន នាង (SAN Neang) (សំណុំរឿង០០២), D230/2/4.2.285b (សំណុំរឿង០០៤ **D191.1.107** ត្រង់ ENG 00629101; ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ិន ស្រាំង (IN Sraing) (សំណុំរឿង០០២), D22/2491/1 (សំណុំរឿង០០៤ **D191.1.22** ត្រង់ ENG 00550791-92) [៥០គូ ត្រូវបានមេឃុំបង្ខំឲ្យរៀបការ]។

[4] ព័ត៌មានបន្ថែមរបស់ កែវ ធារី (KEO Theary) (សំណុំរឿង០០២), D22/2564a ត្រង់ ERN ជាភាសាអង់គ្លេស 00842816 (សំណុំរឿង០០៤ **D5/217.2** ត្រង់ ENG 00842816), D22/2564b ត្រង់ ERN ជាភាសាអង់គ្លេស 00596487 (សំណុំរឿង០០៤ **D287/4.3.1** ត្រង់ ENG 00596487); ព័ត៌មានបន្ថែមរបស់ ស៊ូ រ៉ុន (SOU Ron) (សំណុំរឿង០០២), D22/3342b (សំណុំរឿង០០៤ **D191.1.88** ត្រង់ ENG 00596542) ["ក្រោយរៀបការរួច នៅពេលយប់ ឈ្លបនឹងលបស្តាប់។ បើគូស្រករនោះមិននៅជាមួយគ្នា គេនឹងសម្លាប់ពួកគេចោល"]; ព័ត៌មានបន្ថែមរបស់ ញ៉ឹប ទ្រី (NHIP Try) (សំណុំរឿង០០២), D22/3344b (សំណុំរឿង០០៤

### *ស្រុកព្រៃឈរ (តំបន់ ៤១)*

៣. មានមនុស្សជាច្រើននៅក្នុងស្រុកព្រៃឈរ (ផ្នែកនៃតំបន់ ៤១ នៃភូមិភាគកណ្ដាល) ក៏ត្រូវបានគេដាក់ឲ្យស្ថិតនៅក្រោមគម្រោងអាពាហ៍ពិពាហ៍ដោយបង្ខំដែរ នៅក្នុងសម័យកាលដែល **អោម អាន** ធ្វើជាលេខាតំបន់ ៤១[6]។ អាពាហ៍ពិពាហ៍ទាំងនោះមានការពាក់ព័ន្ធនឹងគូស្រករជាច្រើនរហូតដល់

---

**D191.1.62** ត្រង់ ENG 00596543) ["នៅពេលយប់ ឈ្លបមានកម្លាំងនឹងលបស្ដាប់គូស្រករនោះ។ បើគេដឹងថា គូស្រករនោះមិននៅជាមួយគ្នា គូស្រករនោះនឹងត្រូវគេយកទៅសម្លាប់ចោល"]; ព័ត៌មានបន្ថែមរបស់ មុំ ស្រឿង (MOM Sroeurng) (សំណុំរឿង០០២), D22/3345b (សំណុំរឿង០០៤ **D191.1.57** ត្រង់ ENG 00596544); ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ពិន ដន (PIN Dân) (សំណុំរឿង០០២), E3/4961 ត្រង់ ERN ជាភាសាអង់គ្លេស 00864764 (សំណុំរឿង០០៤ **D5/230** ត្រង់ ENG 00864764) ["គូស្រករដេកជាមួយគ្នានៅយប់នោះ ហើយមានគេលបស្ដាប់"]។

[5] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ពិន ដន (PIN Dân) (សំណុំរឿង០០២), E3/4961 ត្រង់ ERN ជាភាសាអង់គ្លេស 00864764 (សំណុំរឿង០០៤ **D5/230** ត្រង់ ENG 00864764), និងព័ត៌មានបន្ថែម, E3/4962 ត្រង់ ERN ជាភាសាអង់គ្លេស 00842818 (សំណុំរឿង០០៤ **D5/230.1** ត្រង់ ENG 00842818) [កំណត់អត្តសញ្ញាណប្រជាជនថ្មីដែលមានឈ្មោះថា "សមមិត្ត លឹម" ដែលត្រូវបានគេរំលោភសេពសន្ថវៈ]។

[6] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ព្រាប សុខឿន (PREAP Sokhoeurn) (សំណុំរឿង០០២), D22/1983/1 (សំណុំរឿង០០៤ **D191.1.79** ត្រង់ ENG 00541266-00541267), និងព័ត៌មានបន្ថែម, D22/1983a ត្រង់ ERN ជាភាសាអង់គ្លេស 00850589-90 (សំណុំរឿង០០៤ **D191.1.80** ត្រង់ ENG 00850588-90) [ប្រធានអង្គភាពបង្ខំឲ្យរៀបការជាមួយបុរសពិការនៅក្នុងខែតុលា ឆ្នាំ១៩៧៧ ក្នុងការរៀបការជាក្រុមដែលមាន១២គូ]; ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ខូវ ណេត (KHOV Net) (សំណុំរឿង០០២), D22/3899/1 (សំណុំរឿង០០៤ **D191.1.33** ត្រង់ ENG 00571807-00571808) [ត្រូវបានបង្ខំឲ្យរៀបការក្នុងឆ្នាំ១៩៧៨ ជាមួយប្អូនគូទៀត]; ព័ត៌មានបន្ថែមរបស់ សាយ សុខា (SAY Sokha) (សំណុំរឿង០០២), D22/1374a ត្រង់ ERN ជាភាសាអង់គ្លេស 00853121 (សំណុំរឿង០០៤ **D191.1.84** ត្រង់ ENG 00853121) [ការរៀបការចំនួន៣០គូ ដែលប្រធានអង្គចល័តជាអ្នកបង្គាប់ នៅចុងឆ្នាំ១៩៧៨]; ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ជាម ពៅ (CHEAM Pao) (សំណុំរឿង០០២), D22/1482/1 (សំណុំរឿង០០៤ **D191.1.2** ត្រង់ ENG 00529019-20), និងព័ត៌មានបន្ថែម, D22/1482c (សំណុំរឿង០០៤ **D191.1.5** ត្រង់ ENG 00596421)។ អាពាហ៍ពិពាហ៍ដោយបង្ខំរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីខាងក្រោម បានកើតឡើងនៅក្នុងស្រុក កំពង់សៀម ឬ ព្រៃឈរ៖ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ មុំ ស្រឿង (MOM Sroeurng) (សំណុំរឿង០០២), D22/3345/1 (សំណុំរឿង០០៤ **D191.1.56** ត្រង់ ENG 00564601-02), និងព័ត៌មានបន្ថែម, D22/3345b (សំណុំរឿង០០៤ **D191.1.57** ត្រង់ ENG 00596544) [*បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ - សូមមើល D5/33/3*]; ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ផាន យិន (PHAN Yin) (សំណុំរឿង០០២), D22/3725/1 (សំណុំរឿង០០៤ **D191.1.70** ត្រង់ ENG 00569296-97)។

៥០គូ ត្រូវបានគេបង្ខំឲ្យរៀបការនឹងគ្នាក្នុងពេលតែមួយ[7] ហើយអាពាហ៍ពិពាហ៍ទាំងនេះត្រូវបានរៀបចំ និងដឹកនាំធ្វើដោយប្រធានអង្គភាព និងកម្មាភិបាល បកក មូលដ្ឋានផ្សេងទៀត (ដែលពួកគេបានរាយការណ៍តាមឋានានុក្រមនៃខ្មែរក្រហមជូនទៅលេខាតំបន់)[8]។ **អោម អាន** គឺជាលេខាតំបន់៤១ ចាប់ពីខែកុម្ភៈ ឆ្នាំ១៩៧៧ រហូតដល់ខែមករា ឆ្នាំ១៩៧៩[9] ហើយមន្ទីររបស់គាត់ស្ថិតនៅក្នុងភូមិព្រៃទទឹង ស្រុកព្រៃឈរ[10]។

*ស្រុកសង្កែ (តំបន់ ១)*

[7] ព័ត៌មានបន្ថែមរបស់ ជាម ពៅ (CHEAM Pao) (សំណុំរឿង០០២), D22/1482c (សំណុំរឿង០០៤ **D191.1.5** ត្រង់ ENG 00596421 [សាក្សីបានឃើញការរៀបការដោយបង្ខំចំនួន៥០គូ]; ព័ត៌មានបន្ថែមរបស់ សាយ សុខា (SAY Sokha) (សំណុំរឿង០០២), D22/1374a ត្រង់ ERN ជាភាសាអង់គ្លេស 00853121 (សំណុំរឿង០០៤ **D191.1.84** ត្រង់ ENG 00853121) [៣០គូ]។

[8] ព័ត៌មានបន្ថែមរបស់ សាយ សុខា (SAY Sokha) (សំណុំរឿង០០២), D22/1374a ត្រង់ ERN ជាភាសាអង់គ្លេស 00853121 (សំណុំរឿង០០៤ **D191.1.84** ត្រង់ ENG 00853121); ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ព្រាប សុខឿន (PREAP Sokhoeurn) (សំណុំរឿង០០២), D22/1983/1 (សំណុំរឿង០០៤ **D191.1.79** ត្រង់ ENG 00541266-00541267), និងព័ត៌មានបន្ថែម, D22/1983a ត្រង់ ERN ជាភាសាអង់គ្លេស 00850589-90 (សំណុំរឿង០០៤ **D191.1.80** ត្រង់ ENG 00850588-90)។

[9] បទសម្ភាសន៍ អោម អាន របស់ DC-Cam, ១ សីហា ២០១១, ERN ជាភាសាខ្មែរ 00729774-840 (ដែលបានជា**ឧបសម្ព័ន្ធ ២** ភ្ជាប់មកជាមួយ) (សំណុំរឿង០០៤ **D191.2** ត្រង់ ENG 01128485-508 និង 01025310-36); **D117/18** កំណត់ហេតុស្តាប់ចម្លើយរបស់ ពេជ្រ ជិន ដោយ កសចស, A1 [កម្មាភិបាលនិរតី បានបញ្ជូន តា អាន ទៅភូមិភាគកណ្តាល ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧]; **D117/31** កំណត់ហេតុស្តាប់ចម្លើយរបស់ យូ វ៉ាន់ (YOU Van) ដោយ កសចស, A4-A8 & A12; **D117/24** កំណត់ហេតុស្តាប់ចម្លើយរបស់ ពៅ សារុំ (POV Sarom) ដោយ កសចស, A7; **D117/34** កំណត់ហេតុស្តាប់ចម្លើយរបស់ ប្រាក់ នី (PRAK Ny) ដោយ កសចស, A12; **D117/26** កំណត់ហេតុស្តាប់ចម្លើយរបស់ ពុត កុល (PUT Kol) ដោយ កសចស, A4; **D107/15** កំណត់ហេតុស្តាប់ចម្លើយរបស់ បាន សៀក (BAN Siek) ដោយ កសចស, ត្រង់ ERN ជាភាសាអង់គ្លេស 00841965; **D117/20** កំណត់ហេតុស្តាប់ចម្លើយរបស់ លឹម សេង (LIM Seng) ដោយ កសចស, A4; **D3/14** កំណត់ហេតុស្តាប់ចម្លើយរបស់ ណៃ គឹមសាន (NAI Kimsan) ដោយ កសចស, A2; **D3/10** កំណត់ហេតុស្តាប់ចម្លើយរបស់ នីវ ស៊ុន (NIV Sun) ដោយ កសចស, A9; **D107/7** កំណត់ហេតុស្តាប់ចម្លើយរបស់ ញ៉ែម កុល (NHEM Kol) ដោយ កសចស, ត្រង់ ERN ជាភាសាអង់គ្លេស 00787214; **D74** កំណត់ហេតុស្តាប់ចម្លើយរបស់ រដ្ឋ ពៅ (ROTH Peou) ដោយ កសចស, A2-A3 & A6; **D1.3.13.1** សារទូរលេខ ពី កែ ពក ជូនគណៈកម្មាធិការ៨៧០, ២៩ មីនា ១៩៧៨ [យោង "សមមិត្ត អាន នៅតំបន់៤១"]; **D1.3.9.1** បញ្ជីអ្នកទោស ស-២១ "មនុស្សមកពីភូមិភាគឧត្តរ, ១ កុម្ភៈ ១៩៧៧ ដល់ ២៧ មីនា ១៩៧៧", ត្រង់ ERN ជាភាសាអង់គ្លេស 00222967 [លេខាតំបន់៤១ពីមុន ជុន ឈុំ ហៅ តាំង (Chun Chhum alias Taing) ចូល ស-២១ ១៨ កុម្ភៈ ១៩៧៧]។

[10] **D117/24** កំណត់ហេតុស្តាប់ចម្លើយរបស់ ពៅ សារុំ (POV Sarom) ដោយ កសចស, A11; **D107/7** កំណត់ហេតុស្តាប់ចម្លើយរបស់ ញ៉ែម កុល (NHEM Kol) ដោយ កសចស, ត្រង់ ERN ជាភាសាអង់គ្លេស 00787214; **D117/31** កំណត់ហេតុស្តាប់ចម្លើយរបស់ យូ វ៉ាន់ (YOU Van) ដោយ កសចស, A12; **D74** កំណត់ហេតុស្តាប់ចម្លើយរបស់ រដ្ឋ ពៅ (ROTH Peou) ដោយ កសចស, A9; **D1.3.11.42** កំណត់ហេតុស្តាប់ចម្លើយរបស់ រដ្ឋ ពៅ ឬពៅ (ROTH Peou or Pov) ដោយ កសចស, ត្រង់ ERN ជាភាសាអង់គ្លេស 00210541។

៤. មានប្រភពជាច្រើនបានគូសបញ្ជាក់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំដែលបានកើតឡើងនៅក្នុងស្រុកសង្កែ ខេត្តបាត់ដំបង ក្នុងឆ្នាំ១៩៧៨[11]។ អាពាហ៍ពិពាហ៍ទាំងនេះត្រូវបានរៀបចំ និងដឹកនាំធ្វើឡើងដោយកម្មាភិបាល បកក ដូចជា ប្រធានអង្គភាព ឬប្រធានសហករណ៍[12] រួមមានទាំងកម្មាភិបាលមកពីភូមិភាគនិរតី[13]។ អាពាហ៍ពិពាហ៍មហាជនដ៏ធំដែលមានគូស្រករជាច្រើនរហូតដល់៨០គូ ត្រូវបាន

---

[11] មានប្រភពចំនួនប្រាំមកពីស្រុកសង្កែ បញ្ជាក់ថា ការរៀបការរបស់ពួកគាត់បានធ្វើឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៨ ឬក្រោយពេលកម្លាំងពីខាងនិរតី មកដល់: ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចេក សុខា (CHECH Sopha) (សំណុំរឿង០០២), D22/2742/1 (សំណុំរឿង០០៤ **D191.1.6** ត្រង់ ENG 00555992-93), និងព័ត៌មានបន្ថែម, D22/2742b (សំណុំរឿង០០៤ **D191.1.7** ត្រង់ ENG 00587177) [*ហើយក៏បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ ផងដែរ - សូមមើល D5/66/3*]; ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡុង ឈឿម (LONG Chhoeum) (សំណុំរឿង០០២), D22/3216/1 (សំណុំរឿង០០៤ **D191.1.49** ត្រង់ ENG 00562577-80), និងព័ត៌មានបន្ថែម, D22/3216b (សំណុំរឿង០០៤ **D191.1.50** ត្រង់ ENG 00594710); ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ឹម ប៊ុន ឈឿន (IM Bun Chhoeun) (សំណុំរឿង០០២), D22/3815/1 (សំណុំរឿង០០៤ **D191.1.18** ត្រង់ ENG 00570502-04), និងព័ត៌មានបន្ថែម, D22/3815b (សំណុំរឿង០០៤ **D191.1.20** ត្រង់ ENG 00588478-79); ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស្រី សឿម (SREY Soeum) (សំណុំរឿង០០២), D22/3818/1 (សំណុំរឿង០០៤ **D191.1.90** ត្រង់ ENG 00570569-70), និងព័ត៌មានបន្ថែម, D22/3818b (សំណុំរឿង០០៤ **D191.1.92** ត្រង់ ENG 00588482); **D65.1.29b** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សឿង ចាន់តុន (SOEUNG Chanton); ព័ត៌មានបន្ថែមរបស់ សឿង ចាន់តុន (SOEUNG Chanton) (សំណុំរឿង០០២), D22/3895b (សំណុំរឿង០០៤ **D191.1.86** ត្រង់ ENG 00594761-62)។ ប្រភពបួនផ្សេងទៀតមកពីស្រុកនេះ មិនបានបញ្ជាក់ខែ ឬថ្ងៃពិតប្រាកដក្នុងឆ្នាំ ១៩៧៨ទេ: ព័ត៌មានបន្ថែមរបស់ សម វណ្ណា (SORM Vanna) (សំណុំរឿង០០២), D22/2748b (សំណុំរឿង០០៤ **D191.1.87** ត្រង់ ENG 00587180); ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ខឿន ចឹម (KHOEUN Choem) (សំណុំរឿង០០២), D22/3896/1 (សំណុំរឿង០០៤ **D191.1.29** ត្រង់ ENG 00571766-68), និងព័ត៌មានបន្ថែម, D22/3896b (សំណុំរឿង០០៤ **D191.1.31** ត្រង់ ENG 00594763); ព័ត៌មានបន្ថែមរបស់ រាជ សារី (REACH Sary) (សំណុំរឿង០០២), D22/2137b (សំណុំរឿង០០៤ **D191.1.81** ត្រង់ ENG 00585336); ព័ត៌មានបន្ថែមរបស់ ប៊ុត នឿន (BUT Noeun) (សំណុំរឿង០០២), D22/2912b (សំណុំរឿង០០៤ **D65.1.5b** ត្រង់ ENG 00587239-40)។

[12] ព័ត៌មានបន្ថែមរបស់ ចេក សុផា (CHECH Sopha) (សំណុំរឿង០០២), D22/2742b (សំណុំរឿង០០៤ **D191.1.7** ត្រង់ ENG 00587177); ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ឹម ប៊ុន ឈឿន (IM Bun Chhoeun) (សំណុំរឿង០០២), D22/3815/1 (សំណុំរឿង០០៤ **D191.1.18** ត្រង់ ENG 00570502-04), និងព័ត៌មានបន្ថែម, D22/3815b (សំណុំរឿង០០៤ **D191.1.20** ត្រង់ ENG 00588478-79); ព័ត៌មានបន្ថែមរបស់ សឿង ចាន់តុន (SOEUNG Chanton) (សំណុំរឿង០០២), D22/3895b (សំណុំរឿង០០៤ **D191.1.86** ត្រង់ ENG 00594761-62); ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ខឿន ចឹម (KHOEUN Choem) (សំណុំរឿង០០២), D22/3896/1 (សំណុំរឿង០០៤ **D191.1.29** ត្រង់ ENG 00571766-68), និងព័ត៌មានបន្ថែម, D22/3896b (សំណុំរឿង០០៤ **D191.1.31** ត្រង់ ENG 00594763)។

[13] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡុង ឈឿម (LONG Chhoeum) (សំណុំរឿង០០២), D22/3216/1 ត្រង់ ERN ជាភាសាអង់គ្លេស 00562579 (សំណុំរឿង០០៤ **D191.1.49** ត្រង់ ENG 00562579)។

គេបង្ខំឲ្យរៀបការនឹងគ្នាក្នុងពេលតែមួយនោះ ត្រូវបានដឹកនាំធ្វើឡើងនៅក្នុងវត្តរង្សីកេសី[14]។ ក្នុងខែធ្នូ ឆ្នាំ១៩៧៨ ការរៀបការមួយដែលមានចំនួន៨០គូនៅកន្លែងនេះ មានមួយគូត្រូវបានគេបង្ខំដោយផ្ជង់នឹងកាំភ្លើង[15]។ ក្នុងពេលកំពុងរៀបការដែលមានគូស្រករហូតដល់ ៧៥គូ នៅទីកន្លែងដដែលនេះនៅក្នុងឆ្នាំ១៩៧៨ មានបុរសម្នាក់ដែលមិនព្រមរៀបការត្រូវបានគេសម្លាប់ចោល[16]។

៥. ស្រុកសង្កែ (ដែលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមបញ្ចូលនូវផ្នែកខាងកើត នៃអ្វីដែលឥឡូវនេះហៅថា ស្រុកបាណន់) គឺជាផ្នែករបស់តំបន់១ នៃភូមិភាគពាយ្ព័ព្យ[17]។ **យឹម ទិត** *ហៅ* **តា ទិត** បានក្លាយទៅជា លេខាតំបន់១ នៅក្នុងឆ្នាំ១៩៧៨[18]។ ទីតាំងសំខាន់បំផុតរបស់ **យឹម ទិត** នៅក្នុង

---

[14] ព័ត៌មានបន្ថែមរបស់ ចេក សុផា (CHECH Sopha) (សំណុំរឿង០០២), D22/2742b (សំណុំរឿង០០៤ **D191.1.7** ត្រង់ ENG 00587177) [៨០គូ]; ព័ត៌មានបន្ថែមរបស់ សម វណ្ណា (SORM Vanna) (សំណុំរឿង០០២), D22/2748b (សំណុំរឿង០០៤ **D191.1.87** ត្រង់ ENG 00587180) [៧៥គូ]; ព័ត៌មានបន្ថែមរបស់ រាជ សារី (REACH Sary) (សំណុំរឿង០០២), D22/2137b (សំណុំរឿង០០៤ **D191.1.81** ត្រង់ ENG 00585336) [៣០-៤០គូ]។

[15] ព័ត៌មានបន្ថែមរបស់ ចេក សុផា (CHECH Sopha) (សំណុំរឿង០០២), D22/2742b ត្រង់ ERN ជាភាសាអង់គ្លេស 00587177 (សំណុំរឿង០០៤ **D191.1.7** ត្រង់ ENG 00587177)។

[16] ព័ត៌មានបន្ថែមរបស់ សម វណ្ណា (SORM Vanna) (សំណុំរឿង០០២), D22/2748b ត្រង់ ERN ជាភាសាអង់គ្លេស 00587180 (សំណុំរឿង០០៤ **D191.1.87** ត្រង់ ENG 00587180)។

[17] ឯកសារលេខ **D6.1.963** សៀវភៅតក់ត្រា នៃមន្ទីរស-២១, ត្រង់លេខ ERNជាភាសាអង់គ្លេស 00602557 [ កំណត់ហេតុរបស់ តំបន់១ រួមបញ្ចូលទាំងស្រុក បាត់ដំបង,សំឡូត, សង្កែ និង គាស់ក្រឡ ផង] ។ េកសារលេខ **D1.3.10.2** របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ មកពីតំបន់១, ចុះថ្មី២៨ ឧសភា ១៩៧៧, ត្រង់លេខ ERNជាភាសាអង់គ្លេស 00143567-68 [របាយការណ៍ស្តីពីព្រឹត្តការណ៍នៅស្រុកស្ទឹងសង្កែ, ឃុំបែដំរ៉ាម (Bay Damram commune) និង "សមូហភាពស្វាយជាតិ(Svay Cheat collective)"]។ ឯកសារលេខ **D1.3.27.3** របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ពី ម-៥៦០ (M-560), ចុះថ្ងៃទី២៩ ឧសភា ១៩៧៧, ត្រង់លេខ ERNជាភាសាអង់គ្លេស 00183010-11 [យោង មន្ទីរតំបន់១ នៅ "ភូមិឈើទាល(Chheu Teal village)," និងមន្ទីរស្រុកៗសង្កែ " នៅនៅជិត" បែដំរ៉ាម(Bay Damram)]។ឯកសារលេខ **D1.3.11.63** កំណត់ហេតុស្តីពីការធ្វើសម្ភាសន៍នៅខៅអ៊ីដាង លេខ១៤, ចុះថ្ងៃទី១៩ វិច្ឆិកា ១៩៨០, ត្រង់លេខ ERN ជាភាសាអង់គ្លេស 00217612 ["ស្រុកសង្កែ ក្នុងតំបន់១នៃ ភូមិភាគពាយ័ព្យ"]។

[18] ឯកសារលេខ **D118/136,** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ឈាន ហ៊ា (CHHEAN Hea) ដែលស្រង់ដោយ កសចស, ក៨ -ក១៣។ ឯកសារលេខ **D105/8** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ហន ធី (HAN Thy) ដែលស្រង់ដោយ កសចស,ក២៧។ ឯកសារលេខ **D118/18** កំណត់ហេតុស្តីពីការស្តាប់របស់ នួន មួន (NUON Muon) ដែលស្រង់ដោយ កសចស, ក២៧។ ឯកសារលេខ**D118/69** កំណត់ហេតុស្តីពីចម្លើយរបស់ នួន មួន (NUON Muon) ដែលស្រង់ដោយ កសចស, ក១១ -ក១៣ និង ក២២។ ឯកសារលេខ **D118/77** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ណាង នី (NANG Ny) ដែលស្រង់ដោយ កសចស, ក២៣ -ក២៤ [ តំណែងរបស់ តា ទិត ត្រូវបានគេប្រកាសឲ្យដឹងនៅក្នុងអង្គប្រជុំនៅ បែដំរ៉ាម (Bay Damram)]។ ឯកសារលេខ **D118/138** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ទាប ទិត្យ (TIEP Tith) ដែលស្រង់ដោយ កសចស, ក៣៤ -ក៣៦ [តា ទិត បានថ្លែងសន្ទរកថានៅក្នុងមហាសន្និបាត តំបន់៤]។ ឯកសារលេខ **D118/149** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ (HAM Saom) ដែលស្រង់ដោយ កសចស, ក១៩-ក៣២។ ឯកសារលេខ **D1.3.27.5** កំណត់ហេតុស្តីពីការធ្វើសម្ភាសន៍ សាកែវ (Sakeo) លេខ១៨,ចុះថ្ងៃទី៨ មីនា ១៩៨០, ត្រង់លេខ ERN ជាភាសាអង់គ្លេស 00170728 ។ ឯកសារលេខ **D1.3.11.15** កំណត់ហេតុស្តីពីការធ្វើសម្ភាសន៍ ហេង ទាវ *ហៅ* តា ប៉ែត (HENG Teav alias Ta Pèt), ត្រង់លេខ ERN ជាភាសាអង់គ្លេស 00217620, 00426118-19 [អតីតលេខាតំបន់១ ដែលត្រូវបានដាក់ជំនួសដោយ យឹម ទិត (Yim Tith)]។

អម្តុងពេលនោះគឺ ស្រុកសង្កែ ដោយសារបន្ទាប់ពីនោះមកមន្ទីរតំបន់១ បានមកតាំងទីនៅក្នុងស្រុកនោះ[19]។ ហើយ **ទិត** បានស្នាក់នៅត្រង់ទំនប់កង់ហត នឹងបានដឹកនាំការប្រជុំផ្សេងៗនៅឯមន្ទីរស្រុកៗសង្កែ[20]។

៦. លើសពីនេះ ភ័ស្តុតាងដែលបានមកពី កសចស រហូតមកដល់បច្ចុប្បន្ននេះបានបង្ហាញឲ្យឃើញថាតំបន់ទទួលខុសត្រូវរបស់ **យឹម ទិត** នៅពេលគាត់ទើបមកដល់ភូមិភាគពាយ្យ័ព្យ រួមបញ្ចូលទាំងតំបន់៣ និងតំបន់៤ផង ទោះបីជានៅក្នុងអម្តុងពេលមុនការតែងតាំងគាត់ឲ្យធ្វើជាលេខាភូមិភាគនោះក៏ដោយ[21]។ ហេតុដូចនេះគឺ **យឹម ទិត** បានមានសិទ្ធិអំណាចទាក់ទងទៅនឹងការរៀប

---

[19] ឯកសារលេខ **D118/146** របាយការណ៍របស់ កសចស ស្តីពីការកំណត់អត្តសញ្ញាណទីតាំង, ត្រង់លេខ ERN ជាភាសាអង់គ្លេស 00962482-83 [មន្ទីរតំបន់១ កាលនោះស្ថិតនៅត្រង់ទីតាំងនៃមន្ទីរស្រុកបាណន់សព្វថ្ងៃ]។ ឯកសារលេខ **D105/19** របាយការណ៍របស់ កសចស ស្តីពីការកំណត់អត្តសញ្ញាណទីតាំង [មន្ទីរតំបន់១ កាលនោះស្ថិតនៅក្នុង ភូមិឆាយរំផាត់ (Chhay Rumpat village, ឃុំកន្ទឺ២ (Kanteu II commune)]។ ឯកសារលេខ **D118/18** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ នួន មួន (NUON Muon) ដែលស្រង់ដោយ កសចស, ក២៧ -ក២៨។ ឯកសារលេខ **D118/135** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ឆោម យួន (CHHOM Youn) ដែលស្រង់ដោយ កសចស, ក២០។ ឯកសារលេខ **D1.3.27.3** របាយការ ណ៍របស់កម្ពុជាប្រជាធិបតេយ្យមកពីមន្ទីរម-៥៦០ (M-560), ចុះថ្ងៃទី២៩ ឧសភា ១៩៧៧, ត្រង់លេខ ERN ជាភាសាអង់គ្លេស 00183010-11។

[20] ឯកសារលេខ **D118/149** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ហម សោម (HAM Saom) ដែលស្រង់ដោយ កសចស, ក១៧ -ក១៩ និង ក៥៣ [តាទិតបានធ្វើប្រធានដឹកនាំដឹកនាំអង្គប្រជុំនៅមន្ទីរស្រុកសង្កែ ដែលស្ថិតនៅក្បែរស្ពានកង្ហត់ ហើយបានចុះទៅត្រួតពិនិត្យមើលការសាងសង់ទំនប់កង្ហត់]។ ឯកសារលេខ **D118/136** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ឈាន ហ៊ា (CHHEAN Hea) ដែលស្រង់ដោយ កសចស, ក៧, ក១៧ និងក៤៣ ["តាទិត និងតានឹម( Ta Nim) បានមកស្នាក់នៅនឹងទំនប់កង្ហត់។ ហើយពួកគាត់ទាំងពីរនាក់បានចាប់ខ្លួន និងសម្លាប់មនុស្សអស់ជាច្រើននាក់ដែលមកពីតាមសហករណ៍នានានៃស្រុកសង្កែ និងស្រុកបាត់ដំបង"]។ ឯកសារលេខ **D118/77** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ណាងនី (NANG Ny) ដែលស្រង់ដោយ កសចស, ក១ និងក២៣ -ក៣០ [ ទំនប់កង្ហត់ "មានទីតាំងស្ថិតនៅក្នុងកន្ធីទី១ (Kanthi Ti Muoy)" និងផ្នែកនៃតំបន់១]។ ឯកសារលេខ **D118/138** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ទាប ទិត្យ (TIEP Tith) ដែលស្រង់ដោយ កសចស, ,ក៨ [ទំនប់កង្កត់ស្ថិតនៅក្នុងស្រុកសង្កែ, តំបន់១]។ ឯកសារលេខ **D118/135** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ឆោម យួន (CHHOM Youn) ដែលស្រង់ដោយ កសចស, ក២០-ក២១ [អ្នកចាស់មុន យឹម ទិត នោះគឺ តា ប៉ែត, តាប៉ែតមានមូលដ្ឋានស្ថិតនៅឯទំនប់កង្ហត់ (Kang Hât Dam)]។ ឯកសារលេខ **D1.3.4.6** ចម្លើយសារភាពរបស់ គង់ សុផល *ហៅ* កឺ (KONG Sophal alias Keu) ដែលស្រង់ដោយមន្ទីរស-២១, ត្រង់លេខ ERN ជាភាសាអង់គ្លេស 00217745 [ដែលបញ្ជាក់អត្តសញ្ញាណនៃលេខាស្រុកថ្មីនៃស្រុកសង្កែ ដែលមកពីភូមិភាគនិរតី ដែលមានទីតាំងស្ថិតនៅត្រង់ "កង្ហត់(Kanghat)"]។

[21] ឯកសារលេខ **D118/96** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ឡូច អេង (LOCH Eng) ដែលស្រង់ដោយ កសចស, ក២៩ -ក៣៥ [សមាជិកឃុំបឹងព្រៃ, ស្រុកដូនទាវ បាននិយាយថា តា ទិតបានធ្វើប្រធានដឹកនាំអង្គប្រជុំដែលមានការចូលរួមពីគណៈស្រុក និងប្រធានឃុំនានាដែលមកពីតំបន់៤] ។ ឯកសារលេខ **D105/8** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ហាន ធី (HAN Thy) ដែលស្រង់ដោយ កសចស, ក៧ -ក៨។ ឯកសារលេខ **D118/63** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ហាន ធី (HAN Thy) ដែលស្រង់ដោយ កសចស, ក៣៤ -ក៣៥ ។ ឯកសារលេខ **D118/85** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ជា ជឿន (CHEA Choeun) ដែលស្រង់ដោយ កសចស, ក២៦ -ក២៧។ ឯកសារលេខ **D118/153** ឡុង វុន (LONG Vun) ដែលស្រង់ដោយ កសចស, ក៤៥ -ក៤៨ [ភ្នំសំពៅកាលណោះគ្រប់គ្រងដោយ តា ទិត ]។ ឯកសារលេខ **D118/76** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ជុច ពន្លក (CHUCH Punlork) ដែលស្រង់ដោយ កសចស, ក៣៤ -ក៣៦ [ តា ទិត តែងតែចុះទៅត្រួតពិនិត្យមើលការដ្ឋាននៃតំបន់៣ នៅកចំភ្នំសំពៅជាទៀងទាត់ បន្ទាប់ពីការដកកម្មាភិបាលមូលដ្ឋានមួយចំនួននៅក្នុង

អាពាហ៍ពិពាហ៍ដោយបង្ខំ ឬទៅនឹងឧក្រិដ្ឋផ្សេងៗទៀតដែលបានកើតឡើងនៅក្នុងពេលនោះនៅក្នុងភូមិភាគពាយ័ព្យ ពាក់កណ្តាលនៃស្រុកសង្កែសព្វថ្ងៃ (ដែលនៅក្នុងអម្តុងនៃរបបកម្ពុជាប្រជាធិបតេយ្យគឺជាផ្នែកនៅក្នុងតំបន់៤)[22]។

*អំពើហិង្សាផ្លូវភេទប្រឆាំងនឹងខ្មែរក្រោម ជនជាតិវៀតណាម និងក្រុមមុខសញ្ញាផ្សេងៗទៀត*

៧. នៅក្នុងឆ្នាំ១៩៧៨ នៅក្នុងអម្តុងពេលនៃការសម្លាប់ប្រជាជនខ្មែរក្រោម ក្នុងទ្រង់ទ្រាយធំ ដែលធ្វើឡើងដោយកម្មាភិបាលភូមិភាគនីរតី នៅក្នុងស្រុកបាកាន (ផ្នែកនៃតំបន់២ក្នុងភូមិភាគពាយ័ព្យ) ស្ត្រីខ្មែរក្រោមជាច្រើនត្រូវបានគេចាប់រំលោភសេពសន្ថវៈ នៅមុនពេលត្រូវគេសម្លាប់ចោល[23]។ មានប្រភពជាច្រើនបានរាយការណ៍អំពីឧប្បត្តិហេតុនានានៃអំពើហិង្សាផ្លូវភេទ នៅក្នុងស្រុកបាកានក្នុង

ឆ្នាំ១៩៧៨] ។ ឯកសារលេខ **D118/86** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ញ៉ឹក លី (NHOEK Ly) ដែលស្រង់ដោយ កសចស, ក៤ -ក៥និង ក២០ -ក២១ [ការចាប់ខ្លួននៅក្នុងខែកក្កដា ឆ្នាំ១៩៧៨ នៅតំបន់៣ បានសំរេចដោយ តា ម៉ុក និង តា ទិត] ។ ឯកសារលេខ **D119/65** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ទុំ សឿន (TUM Soeun) ដែលស្រង់ដោយ កសចស, ក២២៦ ។ ឯកសារលេខ **D118/87** កំណត់ហេតុស្តីពីចម្លើយរបស់ ទេព ស៊ាន (TEP Sien) ដែលស្រង់ដោយ កសចស, ក២០ -ក២៨ [អនុលេខា ឃុំវត្តករ (Voat (Wat) Kor), ផ្នែកនៃតំបន់៣ បានចូលរួមនៅក្នុងការប្រជុំដែល តា ទិតបានប្រកាសជូនដំណឹងថា " គាត់គឺជាអ្នកទទួលខុសត្រូវលើតំបន់នេះ" ហើយបានតែងតាំងគណៈភូមិ និងគណៈឃុំនានា] ។ ឯកសារលេខ **D118/108** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ លឹម ទឹម (LIM Tim) ដែលស្រង់ដោយ កសចស, ក១៧-ក១៨ [ការតែងតាំង តា ទិតឲ្យទៅកាន់ជាគណៈភូមិភាគពាយ័ព្យ ត្រូវបានប្រកាសឲ្យដឹងនៅពេលសន្និបាតក្នុងពាក់កណ្តាលឆ្នាំ១៩៧៨]។

[22] ឯកសារលេខ **D118/102** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ទាត់ ធឿន (TOAT Thoeun) ដែលស្រង់ដោយ កសចស, ក២៧ ។ ឯកសារលេខ **D6.1.173** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ អ៊ុំ សារឿន (UM Saroeun) ដែលស្រង់ដោយ កសចស, ត្រង់លេខ ERN 00274618។

[23] ពាក្យបណ្តឹងរបស់ ថេប ភុន(THEP Phun) (សំណុំរឿងលេខ០០២), ឯកសារលេខ D230/1.1.863c (សំណុំរឿង០០៤ **D191.1.109** ត្រង់ ENG 00483288-89) [ នៅចុងខែកក្កដា ឆ្នាំ១៩៧៨, ស្ត្រីៗខ្មែរក្រោម និងស្ត្រីភាមិភាគបូព៌ាត្រូវបានកេចាប់រំលោភសេពសន្ថវៈនៅមុនពេលគេសម្លាប់ចោល] ។ ឯកសារលេខ **D118/127** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ពៅ ស៊ីនួន (PEOU Sinuon) ដែលស្រង់ដោយ កសចស, ក៦៥ -ក៧០ ។ ឯកសារលេខ **D6.1.757** កំណត់ហេតុស្តីពីចម្លើយរបស់ ពៅ ស៊ីនួន (POV Sinuon), ដែលស្រង់ដោយ កសចស, ត្រង់លេខ ERN ជាភាសាអង់គ្លេស 00387502 ។ ឯកសារលេខ **D118/125** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ចាប ខួង (CHAB Khuong), ត្រង់លេខ ERN ជាភាសាអង់គ្លេស, ក៨៨ -ក៩១ ។ ឯកសារលេខ **D6.1.758** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ចាប ខួង (CHAB Khuong), , ត្រង់លេខ ERN ជាភាសាអង់គ្លេស 00387496 ។ ឯកសារលេខ **D6.1.142** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ជា លេង (CHEA Leng), , ដែលស្រង់ដោយ កសចស, ត្រង់លេខ ERN ជាភាសាអង់គ្លេស 00279253 ។ *សូមមេត្តាអានផងដែរ* ឯកសារលេខ **D118/163** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ព្រំ សារឿន (PROM Saroeurn), ដែលស្រង់ដោយ កសចស, ក២៦-ក៣១ [ស្ត្រីៗខ្មែរកម្ពុជាក្រោមត្រូវបានគេស្រាតខោអាវអស់នៅខ្លួនទទេរ, ត្រូវបានគេចាប់រំលោភសេពសន្ថវៈ ហើយសម្លាប់ចោលនៅក្បែរភូមិព្រាល (Preal village), ស្រុកគីរីវង្សនៅក្នុងខែកក្កដា ឬ សីហា ឆ្នាំ១៩៧៨]។

ឆ្នាំ១៩៧៨ ប្រឆាំងនឹងពួកអ្នកជម្លៀសពីភូមិភាគបូព៌ា[24] ហើយនឹងពួកខ្មាំងរបស់ បកក ឬក្រុមមុខសញ្ញាផ្សេងៗទៀត[25]។ នៅក្នុងឧប្បត្តិហេតុមួយ ក្នុងចំណោមឧប្បត្តិហេតុទាំងនោះ ដែលបានកើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ មានស្ត្រីមួយក្រុមមានចំនួន៣០នាក់ មកពីភូមិភាគបូព៌ា ត្រូវបានគេសម្រាតសម្លៀកបំពាក់ចេញ ចាប់រំលោភសេពសន្ថវៈ ហើយបានធ្វើទារុណកម្មដោយពួកយោធារបស់បក្ស កុម្មុយនីស្តកម្ពុជា ដែលបានរុកឈើ និងពូថៅចូលទៅក្នុងរន្ធយោនីរបស់ស្ត្រី

---

[24] ឯកសារលេខ **D5/946/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នេត សាវឿន (NET Saveun), ត្រង់លេខ ERN ជាភាសាអង់គ្លេស 00981390-91 ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉េង ឆុន (MENG Chhon) (សំណុំរឿងលេខ០០២), D22/1435/1 ត្រង់លេខ ERN ជាភាសាអង់គ្លេស 00528456 (សំណុំរឿង០០៤ **D191.1.53** ត្រង់ ENG 00528456) [ស្ត្រីៗដែលមកពីភូមិភាគបូព៌ា ត្រូវបានគេចាប់រំលោភសេពសន្ថវៈ នៅមុនគេសម្លាប់ចោល នៅក្នុងស្រុកបាកាន នៅក្នុងផ្នែកបន្ទាប់នៃឆ្នាំ១៩៧៨ ។ ពាក្យបណ្តឹងរបស់ ថេប ភុន (THEP Phun) (សំណុំរឿងលេខ០០២), ឯកសារលេខ D230/1.1.863c (សំណុំរឿង០០៤ **D191.1.109** ត្រង់ ENG 00483288-89)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ុន សារ៉ាត (UN Sarat) (សំណុំរឿងលេខ០០២),ឯកសារលេខ D22/326 ត្រង់លេខ ERN ជាភាសាអង់គ្លេស 00864202 (សំណុំរឿង០០៤ **D191.1.98** ត្រង់ ENG 00864202), និងពត៌មានបន្ថែម, ឯកសារលេខ D22/326b (សំណុំរឿង០០៤ **D191.1.100** ត្រង់ ENG 00590741) [ ពួកស្ត្រីៗដែលត្រូវបានគេចោទថា 'ក្បាលយួនខ្លួនខ្មែរ' ត្រូវបានគេចាប់រំលោភសេពសន្ថវៈ ហើយសម្លាប់ចោល ដោយកងឈ្លបនិរតីនៅក្នុងឆ្នាំ១៩៧៨] ។ ឯកសារលេខ **D65.1.56** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ KHOEM Samon សំណុំរឿងលេខ០០២, ដែលស្រង់ដោយ កសចស, ត្រង់លេខ ENG 00327162-63។ ឯកសារលេខ **D6.1.845** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ ប៉ាង ហន (PANG Han), សំណុំរឿងលេខ០០២, ដែលស្រង់ដោយ កសចស, ត្រង់លេខ ERN ជាភាសាអង់គ្លេស 00402823-24។

[25] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មឺ ពៅ (MEU Peou) (សំណុំរឿងលេខ០០២), ឯកសារលេខ D22/1078/1 (សំណុំរឿង០០៤ **D118/147.1.7.1** ត្រង់ ENG 00518520-21), និង ពត៌មានបន្ថែម, ឯកសារលេខ D22/1078b (សំណុំរឿង០០៤ **D191.1.55** ត្រង់ ENG 00595898-99) [ ការចាប់រំលោភសេពសន្ថវៈចំពោះស្ត្រីនៅមន្ទីរសន្តិសុខត្រាចក្រោល, ស្រុកបាកាន]។ ពត៌មានបន្ថែមរបស់ YIN Roum Doul (សំណុំរឿងលេខ០០២), ឯកសារលេខ D22/2600b (សំណុំរឿង០០៤ **D191.1.104** ត្រង់ ENG 00589372) [ស្ត្រីៗត្រូវបានសចាប់រំលោភសេពសន្ថវៈដោយពួកយោធាខ្មែរក្រហម នៅស្រុកបាកាន នៅចុងឆ្នាំ១៩៧៨]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈឹម ស្រ៊ន (CHHIM Srorn) (សំណុំរឿងលេខ០០២), ឯកសារលេខ E3/5029 ត្រង់លេខ ERN ជាភាសាអង់គ្លេស 00562313 (សំណុំរឿង០០៤ **D191.1.8** ត្រង់ ENG 00562313) [មានស្ត្រីជាច្រើនត្រូវបានចាប់រំលោភដោយពួកឈ្លបខ្មែរក្រហមនៅស្រុកបាកាន ក្នុងឆ្នាំ១៩៧៨]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ហុង សាវ៉ាត (HONG Savath) (សំណុំរឿងលេខ០០២), ឯកសារលេខ E3/4676 ត្រង់លេខ ERN ជាភាសាអង់គ្លេស 00332219 (សំណុំរឿង០០៤ **D191.1.15** ត្រង់ ENG 00332219) [ការចាប់រំលោភសេពសន្ថវៈដោយពួកយោធានៅស្រុកបាកាន ក្នុងឆ្នាំ១៩៧៨]។ ពត៌មានបន្ថែមរបស់ ធង ធន (THORNG Thorn) (សំណុំរឿងលេខ០០២), ឯកសារលេខ D22/3868b (សំណុំរឿង០០៤ **D118/147.1.19.1** ត្រង់ ENG 00595156-57)។ពាក្យបណ្តឹងរបស់ អឿន សំអាត(AOEUN Sam At) (សំណុំរឿងលេខ០០២),ឯកសារលេខ D230/2/4.2.515a (សំណុំរឿង០០៤ **D191.1.106** ត្រង់ ENG 00622964)។ ឯកសារលេខ **D6.1.759** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ គីម សូ (KIM So), , ដែលស្រង់ដោយ កសចស, ត្រង់ ERN ជាភាសាអង់គ្លេស 00388621 [ការចាប់រំលោភអ្នកទោសជាស្ត្រី នៅក្នុងឆ្នាំ១៩៧៨]។ ឯកសារលេខ **D118/124** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ គីម សូ (KIM So), ដែលស្រង់ដោយ កសចស, ក១១៣ -ក១១៦។

ទាំងនោះ [26]។ បន្ទាប់មកទៀត ពួកស្ត្រីទាំងអស់នោះ ត្រូវបានគេសម្លាប់ចោលទាំងអស់ លើកលែងតែស្ត្រីនៅរស់រានមានជីវិតម្នាក់ដែលបានរត់រួច[27]។

៨. **យឹម ទិត** បានក្លាយជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ នៅពាក់កណ្តាលឆ្នាំ១៩៧៨ និងក្រោយមកត្រូវបានតែងតាំងជាលេខាភូមិភាគ[28]។ ក្រៅពីស្រុកបាកាន ខ្មែរក្រោម និងវៀតណាមក៏បានក្លាយជាគោលដៅ និងស្ថិតក្រោមការចាប់ខ្លួន និងការសម្លាប់នៅតាមទីកន្លែងផ្សេងទៀតក្នុងភូមិភាគពាយ័ព្យដែលស្ថិតនៅក្រោមការត្រួតត្រារបស់ **ទិត** ផងដែរ រួមទាំងនៅរោងចក្រស្ករស កំពង់កុល (ដែលស្ថិតនៅក្នុងភូមិតាមៀក ឃុំចែងមានជ័យ និងផ្នែកនៃស្រុកសង្កែតំបន់១ ក្នុងកំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ)[29]។ សហករណ៍ធិបតី (ស្រុកគាស់ក្រឡ តំបន់១)[30]ឃុំរាំងកេសី (ស្រុកសង្កែ)[31] និងភូមិកាច់រទេះ ភូមិថ្មី និងភូមិសាលាត្រាវ នៅក្នុងឃុំកំពង់ព្រាង (ជាផ្នែកនៃស្រុកបាក់ព្រា ហៅស្រុកខ្ពប ហៅស្រុក៤១ តំបន់៤ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ)[32]។

---

[26] ឯកសារលេខ **D5/946/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នេត សាវឿន (NET Saveun), ត្រង់លេខ ERN ជាភាសាអង់គ្លេស 00981390-91។

[27] ឯកសារលេខ **D5/946/1** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នេត សាវឿន (NET Saveun), ត្រង់លេខ ERN ជាភាសាអង់គ្លេស 00981391។

[28] **D118/108** កំណត់ហេតុស្តាប់ចម្លើយរបស់ លឹម ទឹម (LIM Tim) ដោយ កសចស, A17-A18; **D118/136** កំណត់ហេតុស្តាប់ចម្លើយរបស់ ឈៀន ហៀ (CHHEAN Hea) ដោយ កសចស, A7-A13, A23; **D20** កំណត់ហេតុស្តាប់ចម្លើយរបស់ ហាន ធី (HAN Thy) ដោយ កសចស, ERN ជាភាសាអង់គ្លេស 00710286; **D105/8** កំណត់ហេតុស្តាប់ចម្លើយរបស់ ហាន ធី (HAN Thy) ដោយ កសចស, A27; **D118/63** កំណត់ហេតុស្តាប់ចម្លើយរបស់ ហាន ធី (HAN Thy) ដោយ កសចស, A29-A30; **D118/86** កំណត់ហេតុស្តាប់ចម្លើយរបស់ ញឹក លី (NHOEK Ly) ដោយ កសចស, A20-A23; **D118/150** កំណត់ហេតុស្តាប់ចម្លើយរបស់ ហែម មឿន (HEM Moeun) ដោយ កសចស, A60-A61; **D118/69** កំណត់ហេតុស្តាប់ចម្លើយរបស់ នួន មួន (NUON Muon) ដោយ កសចស, A14។

[29] **D118/108** កំណត់ហេតុស្តាប់ចម្លើយរបស់ លឹម ទឹម (LIM Tim) ដោយ កសចស, A17-A19, A22 & A47-A53 ["កម្មកររោងចក្រស្ករស ដែលជាខ្មែរក្រោម ឬវៀតណាម" ត្រូវបានចាប់ខ្លួននៅរោងចក្រស្ករស កំពង់កុល បន្ទាប់ពីបានប្រមូលផ្តុំនៅបាត់ដំបង ដែលពេលនោះ តា ទិត បានណែនាំខ្លួនថាជា "ប្រធានភូមិភាគពាយ័ព្យ" និងបានផ្តល់សុន្ទរកថាបង្គាប់ឲ្យកម្មករ "ការពាររោងចក្រពីវៀតណាម"; **D118/106** កំណត់ហេតុស្តាប់ចម្លើយរបស់ ហួន ជឿម (HUON Choeum) ដោយ កសចស, A12 [ការទទួលខុសត្រូវរបស់ តា ទិត ការការចាប់ខ្លួន និងការតែងតាំងប្រធានថ្មីនៅរោងចក្រស្ករស កំពុងកុល]។

[30] **D65.1.15b** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ កើ សឹង (KEU Seung) [បងប្អូនប្រុស ប្រពន្ធ និងកូនប្រាំបីនាក់ត្រូវបានចាប់ខ្លួននិងសម្លាប់ចោល "ដោយចោទថាជា (យួន)វៀតណាម ដោយសារបានកើតនៅកម្ពុជាក្រោម"]។

[31] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចេក សុផា (CHECH Sopha) (សំណុំរឿង០០២), D22/2742/1 (សំណុំរឿង០០៤ **D191.1.6** ត្រង់ ENG 00555992-93) [ខ្មែរក្រោមនៅ ភូមិរាំងកេសី ត្រូវបានគេចោទថាយួន(វៀតណាម) និងត្រូវបានសម្លាប់ចោល]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ផាន សារង សុផា (PHAN Sarâng) (សំណុំរឿង០០២), D22/2140/1 (សំណុំរឿង០០៤ **D191.1.68** ត្រង់ ENG 00546073-74) [ក្នុងឆ្នាំ ១៩៧៨ កម្មាភិបាលនិរតី តា ឡឹក និង យាយ ចាន់ បានបញ្ជាឲ្យសម្លាប់ខ្មែរក្រោម]; ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ ជូ (KONG Chou) (សំណុំរឿង០០២),

៩. ក្នុងឆ្នាំ១៩៧៧ ស្ត្រីវៀតណាមពីរនាក់ដែលបានធ្លាក់មកដល់ស្រុកព្រះនេត្រព្រះ ត្រូវបានគេរំលោភ និងធ្វើមនុស្សឃាត តាមបញ្ជារបស់កម្មាភិបាលពាយ័ព្យ ដែលជាអ្នកគ្រប់គ្រងបន្តនៅស្រុកនេះ។ យោងតាមប្រធានអង្គភាពបាននិយាយថា អ្នកនៅក្រោមបង្គាប់របស់គាត់គឺជាអ្នកសម្លាប់ផ្ទាល់៖ "មុនដំបូង ស្ត្រីពីរនាក់នោះត្រូវសម្រាកខោអាវ ហើយត្រូវគេចាប់រំលោភ។ បន្ទាប់មក ពួកគេយកឈើរុកចូលក្នុងរន្ធយោនីរបស់ស្ត្រីនោះ ធ្វើឲ្យមានឈាមហូរយ៉ាងខ្លាំង។ បន្ទាប់មកទៀត គេវះពោះស្ត្រីនោះ យកថ្លើមទៅចំអិនស៊ី។ ជនរងគ្រោះទាំងពីរ ខំតស៊ូយ៉ាងវេទនារហូតទាល់តែស្លាប់"[33]។ **អឹម ចែម** គឺជាលេខាស្រុកព្រះនេត្រព្រះនៃ បកក ចាប់ពីខែមិថុនា ១៩៧៧ ដល់ខែមករា ១៩៧៨[34]។

---

D22/3220/1 (សំណុំរឿង០០៤ **D191.1.42** ត្រង់ ENG 00562636-38), និងព័ត៌មានបន្ថែម, D415/2/1.3.1 (សំណុំរឿង០០៤ **D191.1.42** ត្រង់ ENG 00612802) [មនុស្ស១៥០នាក់ នៅភូមិវត្តកណ្តាល (Voat Kandal) រួមទាំងមនុស្ស១៧គ្រួសារ និង២០០នាក់ទៀតនៅភូមិស្វាយជាតិ (Svay Cheat) ត្រូវបានចោទថា "ពាក់ព័ន្ធនឹងយួន(វៀតណាម)" ហើយគេយកទៅសម្លាប់ចោលអស់]; ពាក្យបណ្តឹងរបស់ ថាច់ ង៉ុក ថាច់ (THACH Ngoc Thach) (សំណុំរឿង០០២), D230/2/23 ត្រង់ ERN ជាភាសាអង់គ្លេស 00427058-59 (សំណុំរឿង០០៤ **D5/91** ត្រង់ ENG 00427058-59) [កំណត់អត្តសញ្ញាណទីតាំងក្នុងឃុំរាំងកេសី (Reang Kesei) ជាទីកន្លែងដែលគេសម្លាប់ខ្មែរក្រោម]។

[32] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស សម័យ (SAR Samay) (សំណុំរឿង០០២), D22/2747/1 (សំណុំរឿង០០៤ **D191.1.83** ត្រង់ ENG 00556058-59) [ខ្មែរក្រោមនៅភូមថ្មី ត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់ចោលដោយកម្មាភិបាលនិរតី នៅក្នុងឆ្នាំ១៩៧៨]; ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឃៀម បូ (KHIEM Bo) (សំណុំរឿង០០២), D22/3223/1 (សំណុំរឿង០០៤ **D191.1.27** ត្រង់ ENG 00562677-79) [បងប្អូនស្រី & ប្តី ត្រូវបានចោទថាយួន(វៀតណាម) និងបានសម្លាប់ចោលនៅភូមិកាច់រទេះ]; ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពេជ្រ ឆេវ (PICH Chhev) (សំណុំរឿង០០២), D22/3224/1 (សំណុំរឿង០០៤ **D191.1.77** ត្រង់ ENG 00562690-92) [បងប្អូនដែលគេចោទថា "ជាប់ពាក់ព័ន្ធនឹងយួន(វៀតណាម")  ត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់ចោលនៅភូមិកាច់រទេះ បន្ទាប់ពីកម្មាភិបាលនិរតីមកដល់ក្នុងឆ្នាំ១៩៧៨]; **D65.1.11b** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ហើយ សាន (HAEY San), ត្រង់ ERN ជាភាសាអង់គ្លេស 00562704-05 [បងប្អូនត្រូវបានចោទថា យួន(វៀតណាម") និងត្រូវបានសម្លាប់ចោលនៅភូមិកាច់រទេះ ក្នុងឆ្នាំ១៩៧៨; ពាក្យបណ្តឹងរបស់ ថាច់ ង៉ុក ថាច់ (THACH Ngoc Thach) (សំណុំរឿង០០២), D230/2/23 ត្រង់ ERN ជាភាសាអង់គ្លេស 00427054, 00427058-59 (សំណុំរឿង០០៤ **D5/91** ត្រង់ ENG 00427054 និង 00427058-59) [កំណត់អត្តសញ្ញាណភូមិថ្មី និងគុកសាលាត្រាវ ថាជាទីតាំងសម្លាប់ខ្មែរក្រោម]; ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡុង ឈឿម (LONG Chhoeum) (សំណុំរឿង០០២), D22/3216/1 ត្រង់ ERN ជាភាសាអង់គ្លេស 00562579 (សំណុំរឿង០០៤ **D191.1.49** ត្រង់ ENG 00562579) [ក្នុងឆ្នាំ១៩៧៨ កម្មាភិបាលនិរតី ឈ្មោះ តាឡឹក & យាយ ចាន់ "បានបញ្ជាឲ្យបុគ្គលិកគាត់តាមដាន និងចាប់ខ្លួនមនុស្សយកទៅសម្លាប់"]; **D6.1.625** បទសម្ភាសន៍របស់ អឹក ស៊ីម (OEK Sim), ១៦ តុលា ២០០៥ [កម្មាភិបាលយោធាតំបន់កំណត់អត្តសញ្ញាណ កាច់រទេះ ថាជាទីតាំងនៃទីបញ្ជាយោធាតំបន់]។

[33] **D123/1/2.52** កំណត់ហេតុធ្វើសម្ភាសន៍របស់ ព្រាច រស់ (PHEACH Ruos) ដោយ DC-Cam, ត្រង់ ERN ជាភាសាអង់គ្លេស 00969843-46, 00969850។ *សូមមើលផងដែរ* ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លីម ញ៉ក់ (LIN Nhak) (សំណុំរឿង

01352220



១០. នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្ត្រីដែលជាជនរងគ្រោះនៃការរំលោភសេពសន្ថវៈ ត្រូវទទួលរងទណ្ឌកម្មចំពោះការប្រព្រឹត្តិបទល្មើសសីលធម៌[35] ហើយស្ត្រីភាពច្រើនដែលបានរាយការណ៍អំពីការរំលោភត្រូវបានគេសម្លាប់ចោល[36]។

## *ការបំភ្លឺអំពីវិសាលភាពនៃកិច្ចស៊ើបសួរ*

---

០០២), D22/3119/1 ត្រង់ ERN ជាភាសាអង់គ្លេស 00561706 (សំណុំរឿង០០៤ **D191.1.48** ត្រង់ ENG 00561706) [បងប្អូនស្រីត្រូវបានគេចោទថា យួន(វៀតណាម) និងត្រូវបានគេរំលោភមុនសម្លាប់ក្នុងឆ្នាំ១៩៧៨ នៅក្នុងស្រុកមោង, ខេត្តបាត់ដំបង]។

[34] **D119/73** កំណត់ហេតុស្ដាប់ចម្លើយរបស់ នូ ឈួង (NOU Choung) ដោយ កសចស, A24-A28។ **D119/65** កំណត់ហេតុស្ដាប់ចម្លើយរបស់ ទុំ សឿន (TUM Soeun) ដោយ កសចស, A62-A63, A175។ **D106/5** កំណត់ហេតុស្ដាប់ចម្លើយរបស់ ទុំ សឿន (TUM Soeun) ដោយ កសចស, A11-A13។ **D119/49** កំណត់ហេតុស្ដាប់ចម្លើយរបស់ ធិប សំផាត (THIP Samphat) ដោយ កសចស, A16។ **D119/32** កំណត់ហេតុស្ដាប់ចម្លើយរបស់ ឈឹម ផាន (CHHIM Phan) ដោយ កសចស, A33-A34។ **D118/93** កំណត់ហេតុស្ដាប់ចម្លើយរបស់ ប្រាក់ សឹម (PRAK Soem) ដោយ កសចស, A19។ **D101/1.1** កំណត់ហេតុស្ដាប់ចម្លើយរបស់ ព័រ បណ្ឌិត (POR Bandet) ដោយ កសចស, ត្រង់ ENG 00746366។ **D119/29** កំណត់ហេតុស្ដាប់ចម្លើយរបស់ ផាន ឈួង (PAN Chhuong) ដោយ កសចស, A17។ **D1.3.12.1** បទសម្ភាស អ៊ឹម ចែម (IM Chaem), ២៦ មេសា ២០០៧, ត្រង់ ENG 00217518-20។ **D123/1/5.1a** កំណត់ហេតុស្ដាប់ចម្លើយរបស់ អ៊ឹម ចែម (IM Chaem) ដោយ DC-Cam, ៤ មីនា ២០០៧, ត្រង់ ENG 00089773-74 [អតីតមេដឹកនាំស្រុកព្រះនេត្រព្រះ តាម៉ោង និង (Ta Maong) និង (Ta At) "ត្រូវបានដកចេញ" ក្រោយគាត់ទៅដល់ក្នុងឆ្នាំ១៩៧៧]។ **D1.3.4.1** ចម្លើយសារភាពរបស់ អន ម៉ោង (ÂN Maong) នៅស-២១, ត្រង់ ENG 00786926 [អតីតលេខាស្រុកព្រះនេត្រព្រះ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១០៧៧]។ បញ្ជីឈ្មោះអ្នកទោសស-២១ ដែលកំទេចនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៧, E3/2285 (CF2) ត្រង់ ENG 00873645 [អន ម៉ោង (ÂN Maong) ចូល ស-២១ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧៧]។ ចម្លើយសារភាពរបស់ ម៉ាក់ លឿង ហៅ សំអាត (MAK Leung alias Sâm-At) D82/II-ឧបសម្ព័ន្ធ ១៦ (CF2), ៨ សីហា ១៩៧៧ (សំណុំរឿង០០៤ **D191.1.110** ត្រង់ ENG 00224649 និង 00782187-90) [ប្រធានកងចល័ត ព្រះនេត្រព្រះ - គេហៅថា អនុលេខាស្រុក គ្រប់កន្លែង]។ **D6.1.883** បញ្ជីឈ្មោះអ្នកទោសស-២១ ដែលបានពិនិត្យឡើងវិញរបស់ កសត នៅត្រង់ 00329598 [អន ម៉ោង] [ÂN Maong], 00329822 [ម៉ាក់ លិន *ហៅ* អាត (Mâk Lin *alias* At) ត្រូវបានសម្លាប់នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៧]។

[35] **D118/167** កំណត់ហេតុស្ដាប់ចម្លើយរបស់ វ៉ាន់ សឿន (VAN Soeun) ដោយ កសចស, A127-A129 [អ្នកយាមគុកក្រាំងតាចាន់ និយាយថា ជនរងគ្រោះដោយការរំលោភសេពសន្ថវៈត្រូវមានទោស "ជាអ្នកមានកំហុសស្រាល រីឯអ្នករំលោភគេ ជាអ្នកមានកំហុសធ្ងន់"]។ **D6.1.709** កំណត់ហេតុស្ដាប់ចម្លើយរបស់ ស្រី ថន *ហៅ* ឌុច (SREI Than *alias* Duch) ដោយ កសចស, ត្រង់ A80 ["ទាំងអ្នករំលោភគេ និងអ្នកត្រូវគេរំលោភ ត្រូវតែស្លាប់ ពីព្រោះពួកគេត្រូវបានចោទថាធ្វើខុសនឹងសីលធម៌"]។

[36] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ខេត សុខន (KHET Sokhan) (CF2), D22/1261/1 ត្រង់ ENG 00525014 (សំណុំរឿង០០៤ **D191.1.26** ត្រង់ ENG 00525014) [ស្ត្រី ដែលគេបានរាយការណ៍មកថាត្រូវគេរំលោភ ត្រូវគេចោទខុសសីធម៌ ហើយត្រូវសម្លាប់ចោល]។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ ស ឡៃហ៊ាង (SA Lai Heang) (CF2), E3/4712 ត្រង់ ENG 00446588 (សំណុំរឿង០០៤ **D191.1.82** ត្រង់ ENG 00446588) [ស្ត្រីត្រូវគេហាមឃាត់មិនឲ្យរាយការណ៍ពីការរំលោភសេពសន្ថវៈទេ ហើយត្រូវគេសម្លាប់ចោលបើនិយាយ]។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ កោ សន (KAO Sân) (CF2), D22/208/1 ត្រង់ ENG 00411885 (សំណុំរឿង០០៤ **D191.1.24** ត្រង់ ENG 00411885) [ជនរងគ្រោះ និងអ្នករំលោភគេត្រូវសម្លាប់ចោលទាំងពីរនាក់]។

១១. ដើម្បីជំរះការមន្ទិលសង្ស័យណាមួយ សហព្រះរាជអាជ្ញាអន្តរជាតិ សូមធ្វើការបំភ្លឺថា កិច្ចស៊ើបសួរដែលកំពុងធ្វើឡើងនៅទីតាំងឧក្រិដ្ឋកម្មភ្នំប្រុស និងកុកព្រីង ក្នុងស្រុកកំពង់សៀម ដូចបានរៀបរាប់ក្នុងកថាខណ្ឌ ៣០-៣៣ នៃ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទី៣ (3rd IS ) គឺមានបំណងដើម្បីដាក់បញ្ចូលមន្ទីរសន្តិសុខកំពង់សៀម ដែលមានទីតាំងស្ថិតនៅក្នុង វត្តអង្គចដីនៅក្នុងឃុំក្រឡា និងទីតាំងសម្លាប់មនុស្សដែលពាក់ព័ន្ធនៅក្នុងភូមិទួលបេង ដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានដឹកនាំធ្វើឡើងដោយអ្នកស៊ើបអង្កេត កសចស[37]។

១២. សហព្រះរាជអាជ្ញា សូមធ្វើការបំភ្លឺបន្ថែមថា ការចាប់ខ្លួន ការសម្លាប់ និងឧក្រិដ្ឋកម្មដទៃទៀតដែលបានប្រព្រឹត្តឡើងនៅទីតាំងទំនប់កង់ហាត នៅក្នុងសម័យកាលដែល **យឹម ទិត** ធ្វើជាលេខាតំបន់ ១ គឺមានបំណងដើម្បីបញ្ចូលទៅក្នុងកិច្ចស៊ើបសួរដែលកំពុងតែធ្វើនូវការដ្ឋានទួលម្ទេស មន្ទីរសន្តិសុខតំបន់១ និងការបោសសម្អាតនៅភូមិភាគពាយ័ព្យ។

[37] **D117/32** កំណត់ហេតុស្តាប់ចម្លើយរបស់ ញ៉ែម កុល (NHEM Kol) ដោយ កសចស, A9-A12។ **D117/34** កំណត់ហេតុស្តាប់ចម្លើយរបស់ ប្រាក់ នី (PRAK Ny) ដោយ កសចស, A3។ **D117/33** កំណត់ហេតុស្តាប់ចម្លើយរបស់ ពៅ សារ៉ុម (POV Sarom) ដោយ កសចស, A9-A10។ **D117/26** កំណត់ហេតុស្តាប់ចម្លើយរបស់ ពុត កុល (PUT Kol) ដោយ កសចស, A25។ **D117/31** កំណត់ហេតុស្តាប់ចម្លើយរបស់ យូ វ៉ាន់ (YOU Van) ដោយ កសចស, A20។ **D107/6** កំណត់ហេតុស្តាប់ចម្លើយរបស់ ឆេង យឿន (CHHENG Yeun) ដោយ កសចស, ត្រង់ ENG 00787194។ *សូមអានផងដែរ* **D127/2.1.9** សក្ខីកម្មសវនាការរបស់ ប្រាក់ យុត (PRAK Yut), ៣០ មករា ២០១២, ទំព័រ៦១។ **D6.1.730** កំណត់ហេតុស្តាប់ចម្លើយរបស់ ប្រាក់ យុត (PRAK Yut) ដោយ កសចស, ត្រង់ ENG 00364083។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឈួន ផន (CHUON Phân) (CF2), D22/2442/1 (សំណុំរឿង០០៤ **D191.1.13** ត្រង់ ENG 00551505-06), និង ព័ត៍មានបន្ថែម, D22/2442b (សំណុំរឿង០០៤ **D191.1.14** ត្រង់ ENG 00596975) [ឪពុកត្រូវគេឃុំខ្លួននៅគុកវត្តអង្គញដី ហើយគេសម្លាប់ចោលនៅក្បែរភ្នំប្រុស ក្នុងឆ្នាំ១៩៧៨]។ កំណត់ហេតុស្តាប់ចម្លើយរបស់ ណាត ហឿន (NAT Hoeun) ដោយ កសចស, CF3, D43 ត្រង់ ENG 00797020-22 (សំណុំរឿង០០៤ **D191.1.112** ត្រង់ ENG 00797020-22)។ ពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីរបស់ ណាត ហឿន (NAT Hoeun) ដោយ កសចស, (CF2), D22/3733/1 (សំណុំរឿង០០៤ **D191.1.60** ត្រង់ ENG 00569346-47)។ ព័ត៍មានបន្ថែមរបស់ ឡេង យឹម (LENG Yim), (CF2), D22/3390c (សំណុំរឿង០០៤ **D191.1.46** ត្រង់ ENG 00596562)។ ព័ត៍មានបន្ថែមរបស់ អ៊ុំ វិបុល (OM Vibol), (CF2), D22/592a (សំណុំរឿង០០៤ **D191.1.63** ត្រង់ ENG 00858204-06)។ ព័ត៍មានបន្ថែមរបស់ ផ្លុង ហ៊ាន (PHLONG Hean), (CF2), D22/3366b (សំណុំរឿង០០៤ **D191.1.72** ត្រង់ ENG 00596546)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស៊ុម ចាន់ (SUM Chan), (CF2), D22/2577/1 (សំណុំរឿង០០៤ **D191.1.93** ត្រង់ ENG 00552793-94)។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ថាន់ ណាន់ (THAN Nan), (CF2), D22/3386/1 (សំណុំរឿង០០៤ **D191.1.94** ត្រង់ ENG 00564975-76), និងព័ត៍មានបន្ថែម, D22/3386b (សំណុំរឿង០០៤ **D191.1.95** ត្រង់ ENG 00596978)។

## ការកំណត់បទចោទ

១៣. សហព្រះរាជអាជ្ញា មានមូលហេតុដែលនាំឲ្យជឿបានថា អង្គហេតុនានាដូចបានរៀបរាប់ខាងលើ រួមបង្កើតបានជាឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការ ដែលរួមមានប៉ុន្តែមិនកំណត់ត្រឹមអ្វីដូចមានចែងខាងក្រោមនេះទេ៖

ក. មនុស្សឃាត និងទារុណកម្ម ដែលជាការរំលោភ **ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦** (មាត្រា៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ & ៥០៨) ត្រូវផ្តន្ទាទោសតាមមាត្រា៣ (ថ្មី), មាត្រា២៩ (ថ្មី), និងមាត្រា៣៩ (ថ្មី) នៃច្បាប់ អ.វ.ត.ក។

ខ. ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ឬ ពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលបង្កើតបានជា **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ត្រូវផ្តន្ទាទោសតាមមាត្រា៥ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ អ.វ.ត.ក។

១៤. សហព្រះរាជ មានមូលហេតុដែលនាំឲ្យជឿបានថា **យឹម ទិត ហៅ តា ទិត**, **អោម អាន ហៅ តា អាន**, **អឹម ចែម** និងមេដឹកនាំជាន់ខ្ពស់ដទៃទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំង **នួន ជា** និង**ខៀវ សំផន** បានប្រព្រឹត្ត បានធ្វើផែនការ បានញុះញង់ បានបញ្ជា និងបានជួយ និងទំនុកបម្រុង ដល់អំពើព្រហ្មទណ្ឌជាក់លាក់ ដូចបានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះ ដែលជាបទល្មើសមានចែងនៅក្នុងច្បាប់ អ.វ.ត.ក។ អំពើទាំងនេះ គឺជាផ្នែកនៃផែនការឧក្រិដ្ឋកម្មរួម ឬសហកម្មឧក្រិដ្ឋកម្មរួម ដូចបានរៀបរាប់ក្នុងកថាខណ្ឌ២១នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ និងកថាខណ្ឌ១៦ ដល់១៧ នៃ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទី៣ (3rd IS)។

១៥. ឯកសារដែលបានលើកយោងនៅក្នុងដីកាសន្និដ្ឋាននេះ គឺថ្មី ឬយកចេញពីសំណុំរឿង ០០២ ឬ០០៣ និងដែលបានស្នើឲ្យដាក់បញ្ចូលទៅក្នុងសំណុំរឿង០០៤ មានរាយឈ្មោះនៅក្នុងឧបសម្ព័ន្ធ ១ ដែលភ្ជាប់ជាមួយនេះ។ កសចស បានចូលពិនិត្យឯកសារសម្ងាត់ក្នុងសំណុំរឿង០០២ តាមការណែនាំ

របស់អង្គជំនុំជម្រះសាលាដំបូង និងបានទទួលការអនុញ្ញាតឲ្យដាក់ឯកសារនោះចូលក្នុងសំណុំរឿងនេះ[38]។

១៦. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះ ត្រូវបានចុះហត្ថលេខាដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯងប៉ុណ្ណោះ ហេតុដូច្នេះការដាក់ឯកសារនេះ គឺបានធ្វើឡើងស្របតាមវិធាន៧១(៣)។ កំណត់ហេតុនៃការខ្វែងយោបល់គ្នា បានដាក់ទៅក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែក ដែលបានរក្សាទុកដោយក្រឡាបញ្ជីនៃការិយាល័យសហព្រះរាជអាជ្ញា អនុលោមតាមវិធាន៧១(១)៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ | **លោក** Nicholas KOUMJIAN **សហព្រះរាជអាជ្ញាអន្តរជាតិ** | ភ្នំពេញ | |

[38] **D127/1** , អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២។